សុខភាព និងជីវិត
កាន់តែប្រសើរ

# AIA សម្រាប់ជីវិត

# 2ការពារ5⁺ប្រាក់ត្រលប់

ដំណោះស្រាយការពារហិរញ្ញវត្ថុគ្រួសាររបស់លោកអ្នករយៈពេល5ឆ្នាំ ជាមួយនឹងការបង់បុព្វលាភធានារ៉ាប់រងត្រឹមតែ2ឆ្នាំ រួមទាំងប្រាក់ត្រលប់មកវិញ



សូមណែនាំ **AIA សម្រាប់ជីវិត 2ការពារ5$^+$ប្រាក់ត្រលប់** ដែលជាដំណោះស្រាយការពារហិរញ្ញវត្ថុគ្រួសាររបស់លោកអ្នករយៈពេល 5 ឆ្នាំ ក្នុងករណីមានគ្រោះអកុសណាមួយកើតឡើង ជាមួយនឹងការបង់បុព្វលាភធានារ៉ាប់រងត្រឹមតែ2 ឆ្នាំ និងប្រាក់ត្រលប់មកវិញនៃបុព្វលាភធានារ៉ាប់រងឆ្នាំទី 1 នៅចុងបញ្ចប់នៃរយៈពេលធានារ៉ាប់រងរបស់លោកអ្នក។



## លោកអ្នកនឹងទទួលបានអត្ថប្រយោជន៍នៃការការពារដូចជា៖

### ធានាសុវត្ថិភាពហិរញ្ញវត្ថុគ្រួសារ

ក្នុងករណីមានគ្រោះអកុសលដែលបង្កឡើងពីជំងឺឬគ្រោះថ្នាក់ចៃដន្យ ហើយបណ្តាលឲ្យពិការ ឬទទួលមរណភាព AIA នឹងផ្តល់សំណងជូនលោកអ្នក ឬគ្រួសារ ដែលសំណងនោះគឺអាចជួយគ្រួសារ និងលោកអ្នកមិនឲ្យធ្លាក់ក្នុងវិបត្តិហិរញ្ញវត្ថុ។

### បង់ត្រឹមតែ 2 ឆ្នាំ ទទួលបានការការពារហិរញ្ញវត្ថុរហូត 5 ឆ្នាំ

លោកអ្នកបង់បុព្វលាភធានារ៉ាប់រងត្រឹមតែ2ឆ្នាំ ហើយទទួលបានការការពារហិរញ្ញវត្ថុរហូតដល់ទៅ5ឆ្នាំ។

### ទទួលបានប្រាក់ត្រលប់មកវិញចំនួន 60% នៃបុព្វលាភធានារ៉ាប់រងឆ្នាំទី1

លោកអ្នកមិនត្រឹមតែទទួលបានការការពារហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានប្រាក់ត្រលប់មកវិញចំនួន 60% នៃបុព្វលាភធានារ៉ាប់រងឆ្នាំទី1 នៅចុងបញ្ចប់នៃរយៈពេលធានារ៉ាប់រងរបស់លោកអ្នក។

### ទទួលបានការបញ្ចុះតម្លៃ30% លើការបង់បុព្វលាភធានារ៉ាប់រង

លោកអ្នកនឹងទទួលបានការបញ្ចុះតម្លៃពិសេសបន្ថែម 30% លើបុព្វលាភធានារ៉ាប់រងឆ្នាំទី 2 ប្រសិនលោកអ្នកជ្រើសរើសបង់ផ្តាច់នូវបុព្វលាភធានារ៉ាប់រងទាំងអស់ក្នុងឆ្នាំទី 1។

## ងាយស្រួល និងឆាប់រហ័ស

### លោកអ្នកអាចទទួលបានការការពារហិរញ្ញវត្ថុបានយ៉ាងឆាប់រហ័ស និងងាយស្រួលដោយគ្រាន់តែ៖

- ជួបពិភាក្សាជាមួយទីប្រឹក្សាផែនការជីវិត AIA
- ឆ្លើយសំណួរទាក់ទងនឹងស្ថានភាពសុខភាព (មិនតម្រូវឲ្យមានការពិនិត្យសុខភាព)
- ទទួលបានការធានារ៉ាប់រងក្នុងរយៈពេល1ថ្ងៃបន្ទាប់ពី AIA ទទួលបានឯកសារ និងព័ត៌មានគ្រប់គ្រាន់។

ដំណោះស្រាយការពារហិរញ្ញវត្ថុគ្រួសាររបស់លោកអ្នករយៈពេល5ឆ្នាំ ជាមួយនឹងការបង់បុព្វលាភធានារ៉ាប់រងត្រឹមតែ2ឆ្នាំ រួមទាំងប្រាក់ត្រលប់មកវិញ



## សង្ខេបអំពី AIA សម្រាប់ជីវិត 2ការពារ5⁺ប្រាក់ត្រលប់

| | | | |
|---|---|---|---|
| រយៈពេលនៃបណ្ណសន្យារ៉ាប់រង | 5 ឆ្នាំ | | |
| រយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង | 2 ឆ្នាំ | | |
| អាយុដែលត្រូវបានអនុញ្ញាត | 18 ដល់ 60 ឆ្នាំ | | |
| កញ្ចប់ | កញ្ចប់ 3ពាន់ | កញ្ចប់ 5ពាន់ | កញ្ចប់ 7ពាន់ |
| អត្ថប្រយោជន៍លើមរណភាពឬពិការភាពមិនបង្កដោយគ្រោះថ្នាក់ចៃដន្យ* | US$3,000 | US$5,000 | US$7,000 |
| អត្ថប្រយោជន៍លើមរណភាពឬពិការភាពបង្កដោយគ្រោះថ្នាក់ចៃដន្យ** | US$9,000 | US$15,000 | US$21,000 |
| បុព្វលាភធានារ៉ាប់រងត្រលប់វិញ | 60% នៃបុព្វលាភធានារ៉ាប់រងឆ្នាំទី1 | | |

សម្គាល់៖
* សំដៅទៅលើ (1) អត្ថប្រយោជន៍ការពារគ្រួសារ ឬ (2) អត្ថប្រយោជន៍លើការស្តារនីតិសម្បទា
* * សំដៅទៅលើ (1) អត្ថប្រយោជន៍ការពារគ្រួសារ ឬ (2) អត្ថប្រយោជន៍លើការស្តារនីតិសម្បទា និង(3) អត្ថប្រយោជន៍បន្ថែមលើមរណភាព និងពិការភាពដោយគ្រោះថ្នាក់ចៃដន្យ

ដំណោះស្រាយការពារហិរញ្ញវត្ថុគ្រួសាររបស់លោកអ្នករយៈពេល5ឆ្នាំ ជាមួយនឹងការបង់បុព្វលាភធានារ៉ាប់រងត្រឹមតែ2ឆ្នាំ រួមទាំងប្រាក់ត្រលប់មកវិញ

# សម្រាប់អតិថិជនមានគោលដៅសន្សំសម្រាប់បង់រំលស់ផ្ទះ

លោក សុធា មានអាយុ 30ឆ្នាំ រៀបការរួច និងមានកូនស្រី1 នាក់។ គាត់បានបើកគណនី ដើម្បីសន្សំប្រាក់សម្រាប់ទុកបង់រំលស់ផ្ទះដ៏កក់ក្ដៅមួយ។ ដើម្បីឲ្យប្រាកដថាគម្រោងសន្សំរបស់គាត់មិនមានការប្រែប្រួលទោះបីមានគ្រោះអកុសលណាមួយកើតឡើងក៏ដោយ គាត់បានពិភាក្សាជាមួយទីប្រឹក្សាផែនការជីវិត AIA អំពីអត្ថប្រយោជន៍របស់ **AIA សម្រាប់ជីវិត 2ការពារ5⁺ប្រាក់ត្រលប់** កញ្ចប់ 7ពាន់។



## គោលដៅរបស់លោក សុធា



ប្រាកដថាគម្រោងសន្សំបង់រំលស់ផ្ទះរបស់គាត់មិនមានការប្រែប្រួល



មិនចង់ឲ្យគ្រួសារធ្លាក់ក្នុងវិបត្តិហិរញ្ញវត្ថុ



ទទួលបានប្រាក់ត្រលប់មកវិញនៃបុព្វលាភធានារ៉ាប់រងដែលគាត់បានបង់នៅចុងបញ្ចប់នៃបណ្ណសន្យារ៉ាប់រង

## តើលោក សុធា និងគ្រួសារទទួលបានអត្ថប្រយោជន៍អ្វីខ្លះពី AIA សម្រាប់ជីវិត 2ការពារ5⁺ប្រាក់ត្រលប់?

### ក្នុងករណីមានគ្រោះអកុសណាមួយកើតឡើង៖

បន្ទាប់ពីទទួលបានការធានា 1ឆ្នាំ លោក សុធា ជួបប្រទះគ្រោះថ្នាក់ចៃដន្យបណ្ដាលឲ្យគាត់ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។ ក្នុងនាមជាមេគ្រួសារលោក សុធានឹងទទួលបានសំណងចំនួន US$21,000 ពី AIA ។
លោក សុធា និងគ្រួសារ អាចយកប្រាក់នេះទៅប្រើប្រាស់ដើម្បីផ្គត់ផ្គង់ជីវិតភាពបានមួយរយៈរហូតដល់ពេលគ្រួសារលោកសុធាអាចរកដំណោះស្រាយផ្សេងៗទៀតបាន។

ពួកគាត់ក៏អាចប្រើប្រាស់ប្រាក់នេះសម្រាប់ទុកបង់រំលស់ផ្ទះ។

- បន្ទាប់ពីសំណងត្រូវបានទូទាត់ បណ្ណសន្យារ៉ាប់រងរបស់លោក សុធា ក៏ត្រូវបានបញ្ចប់សុពលភាពផងដែរ។

### ក្នុងករណីគ្រប់យ៉ាងមានសុខសុវត្ថិភាព៖

ក្នុងករណីមិនមានគ្រោះអកុសលណាមួយកើតឡើងក្នុងរយៈពេល5ឆ្នាំ ហើយបណ្ណសន្យារ៉ាប់រងរបស់លោក សុធា ឈានដល់កាលកំណត់។ គាត់ទទួលបានប្រាក់ត្រលប់មកវិញចំនួន US$321.42 ពី AIA ។

- បន្ទាប់ពីប្រាក់ត្រលប់ត្រូវបានទូទាត់ បណ្ណសន្យារ៉ាប់រងរបស់លោក សុធា ក៏ត្រូវបានបញ្ចប់សុពលភាពផងដែរ។

ព័ត៌មានក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺសម្រាប់ជាព័ត៌មានបឋមតែប៉ុណ្ណោះ។ សម្រាប់ព័ត៌មានលម្អិត និងលក្ខខណ្ឌនៃការផ្ដល់ជូន សូមទាក់ទងទីប្រឹក្សាផែនការជីវិត **AIA** ឬទាក់ទងផ្នែកសេវាកម្មអតិថិជនរបស់ **AIA** **086 999 242** ឬ **023 999 242**។